វ៉ុល១ លេខទី២ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩

# ការពន្យល់ពីសង្គ្រាមពាណិជ្ជកម្មអាមេរិក-ចិន

ជា មុយគីម*

ការចរចាពាណិជ្ជកម្មរវាងអាមេរិក និងចិនបច្ចុប្បន្នកំពុងស្ថិតក្នុងជុំទី១១ ប៉ុន្តែដូចការចរចាពីមុនៗដែរ វាបានបញ្ចប់ទៅដោយគ្មានន័យ។ សេដ្ឋកិច្ចវិទូ និងអ្នកវិភាគ បានរំពឹងទុកយ៉ាងខ្ពស់ទៅលើការចរចាពាណិជ្ជកម្មលើកនេះ ដោយសង្ឃឹមថាកិច្ចព្រមព្រៀងសេដ្ឋកិច្ចដែលគេតែងរំពឹងទុកមកជាយូរមកហើយនោះ នឹងត្រូវបានសម្រេចក្នុងជុំនេះ។ តែការរំពឹងទាំងនោះត្រូវសាបរលាយក្រោយពេល លោក ដូណាល់ ត្រាំ ធ្វើការគំរាមតម្លើងពន្ធលើទំនិញនាំចូលពីចិនដោយកំរោល នៅពីរថ្ងៃមុនការចរចាផ្នែកពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដែលការគំរាមនេះ គឺទៅលើទំនិញចិនដែលមានតម្លៃប្រមាណ ៣២៥ ពាន់លានដុល្លារអាមេរិក ដោយសហរដ្ឋអាមេរិកបានលើកហេតុផលថា ប្រទេសចិនបានក្បត់កិច្ចសន្យា។ ទោះបីជាការចរចាដែលមានតែឈ្មោះនេះ នៅតែបន្តតាមការគ្រោងទុក ភាគីទាំងពីរមិនបានចេញជាវិធានការណាមួយដើម្បីដោះស្រាយទំនាស់សេដ្ឋកិច្ចនេះឡើយ។ អ្វីដែលគេសង្កេតឃើញមានដំណើរការទៅមុខនៅក្នុងសង្គ្រាមពាណិជ្ជកម្មមួយនេះ គឺតម្លៃពន្ធដែលចេះតែកើនឡើង និងការរីករាលដាលនៃផលប៉ះពាល់ដែលកើតឡើងពីការតម្លើងពន្ធនេះ។ ស្ថានការណ៍ដែលអាមេរិក និងចិនកំពុងប្រឈមមុខគ្នានេះ កំពុងតែបង្កើតជាសង្គ្រាមពាណិជ្ជកម្មរវាងប្រទេស ដែលមានសេដ្ឋកិច្ចធំជាងគេបំផុតក្នុងពិភពលោកទាំងពីរ ហើយសង្គ្រាមពាណិជ្ជកម្មនេះអាចនឹងជះឥទ្ធិពលអវិជ្ជមានដ៏ធំធេងដល់សេដ្ឋកិច្ចពិភពលោកទាំងមូល។ ប៉ុន្តែតើអ្វីទៅគឺជាសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន ដែលកំពុងតែកើតមានឡើងក្នុងពេលបច្ចុប្បន្ន? ហើយតើអ្វីទៅដែលនាំឱ្យមានព្រឹត្តិការណ៍នេះកើតមានឡើង? ហើយអ្វីដែលសំខាន់ជាងគេនោះ តើសង្គ្រាមពាណិជ្ជកម្មនេះ នាំឱ្យមមានផលប៉ះពាល់អ្វីខ្លះមកទល់ពេលនេះ? មុននឹងធ្វើការស្វែងយល់ឱ្យបានស៊ីជម្រៅ ទាក់ទងនឹងសង្គ្រាមពាណិជ្ជកម្ម ដែលគួរអោយព្រួយបារម្ភរវាងអាមេរិក និងចិន គេត្រូវយល់ច្បាស់ជាមុនសិនអំពីអ្វីទៅជា "សង្គ្រាមពាណិជ្ជកម្ម"។

### ❖ តើអ្វីទៅជាសង្គ្រាមពាណិជ្ជកម្ម?

សង្គ្រាមពាណិជ្ជកម្ម គឺជាស្ថានភាពមួយដែលជម្លោះសេដ្ឋកិច្ចរវាងប្រទេសមួយ និងប្រទេសមួយទៀត កើតចេញពីការអនុវត្តគោលនយោបាយការពារនិយមខ្លាំង។ សង្គ្រាមពាណិជ្ជកម្ម ត្រូវបានបង្កឡើងនៅពេលប្រទេសមួយ បង្កើន ឬដាក់ពន្ធ/កូតាទៅលើទំនិញនាំចូលពីប្រទេសមួយ ឬច្រើន ហើយភាគីម្ខាងទៀតតបតទៅវិញជាមួយនឹងទម្រង់បែបការពារនិយមដូចគ្នា។ ការអនុវត្តបែបនេះបន្តទៅវិញទៅមក គឺនឹងនាំឱ្យសង្គ្រាមពាណិជ្ជកម្មកើតមានឡើង។ សង្គ្រាមពាណិជ្ជកម្ម ធ្លាប់ត្រូវបានយកមកអនុវត្តជាញឹកញាប់ដោយសហរដ្ឋអាមេរិក ក្នុងគោលបំណងផ្តល់ការការពារដល់អាជីវកម្មក្នុងស្រុក និងលើកកម្ពស់សេដ្ឋកិច្ចរបស់អាមេរិក ដែលគេតែងឃើញមានការអនុវត្តដដែលបែបនេះ នៅក្នុងប្រវត្តិសាស្ត្រនៃសង្គ្រាមពាណិជ្ជកម្ម[1]។ សង្គ្រាមពាណិជ្ជកម្មចុងក្រោយបង្អស់ គឺនៅក្នុងឆ្នាំ១៩៩៤ ក្រោយពីសហរដ្ឋអាមេរិក និងកាណាដាបានដោះស្រាយជម្លោះពាណិជ្ជកម្មរបស់ពួកគេ និងធ្វើទំនាក់ទំនងពាណិជ្ជកម្មទៅមកជាមួយគ្នាជាធម្មតាវិញ។ រយៈពេលចុងក្រោយនេះចាប់តាំងពីឆ្នាំ២០១៨ គេឃើញមានសញ្ញានៃការលេចចេញជាថ្មីនៃសង្គ្រាមពាណិជ្ជកម្មមួយទៀត បន្ទាប់ពីភាពស្ងៀមស្ងាត់អស់រយៈពេល

[1] International Relations EDU. (May 17, 2018). *Top 5 Trade Wars Throughout History*. Retrieved from: https://www.internationalrelationsedu.org/2018/05/top-5-trade-wars-throughout-history/

*ជា មុយគីម ជាអ្នកសម្របសម្រួលការស្រាវជ្រាវ និងផ្សព្វផ្សាយ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

២០ឆ្នាំមកនេះ។ ពេលនេះ គឺរវាងប្រទេសមហាអំណាចសេដ្ឋកិច្ចពិភពលោកទាំងពីរ៖ អាមេរិក និងចិន។

### ❖ តើសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន កើតឡើងពេលណា និងដោយរបៀបណា?

សង្គ្រាមពាណិជ្ជកម្ម បានកើតឡើងពីព្រឹត្តិការណ៍នៃការគំរាមកំហែងមួយចំនួនរវាងអាមេរិក និងចិន។ មួយផ្នែកធំនៃប្រជាប្រិយភាពរបស់លោក ត្រាំ នៅក្នុងយុទ្ធនាការបោះឆ្នោតជ្រើសរើសប្រធានាធិបតី គឺបានមកពីការអះអាង លើការជួយសង្គ្រោះសហរដ្ឋអាមេរិកពីឱនភាពពាណិជ្ជកម្ម ដែលប្រទេសនេះកំពុងប្រឈមពីការធ្វើពាណិជ្ជកម្ម ជាមួយនឹងដៃគូពាណិជ្ជកម្មរបស់ខ្លួនសព្វថ្ងៃ។ ប៉ុន្តែបន្ទាប់ពីលោក ត្រាំ បានជាប់ឆ្នោត ហើយឡើងកាន់តំណែងនៅឆ្នាំ២០១៧ ឱនភាពពាណិជ្ជកម្មអាមេរិកកាន់តែធ្លាក់ដុនដាបជាងមុន និងបានធ្វើឱ្យចំនួននៃឱនភាពពាណិជ្ជកម្មកើនឡើងដល់ចំនួន ៨១០ ពាន់លានដុល្លារអាមេរិកនៅក្នុងពាណិជ្ជកម្មទំនិញ ដែលតួរលេខនេះបានឈានដល់កំណត់ត្រាខ្ពស់បំផុត ក្នុងរយៈពេលប្រាំបួនឆ្នាំចុងក្រោយ (Wiseman, 2018)។

ជាក់ស្តែង នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ សហរដ្ឋអាមេរិកបានប្រកាសដាក់បន្ថែមពន្ធគយលើផលិតផលនាំចូលជាបន្តបន្ទាប់ រួមមានបន្ទះសូឡា ម៉ាស៊ីនបោកគក់ ដែកថែប និងអាលុយមីញ៉ូម ដោយដាក់ពន្ធ ៣០ភាគរយ ២០ភាគរយ ២៥ភាគរយ និង១០ភាគរយទៅលើមុខទំនិញដែលបានរៀបរាប់ខាងលើ។ ការដាក់បន្ថែមពន្ធទាំងនោះមិនបានផ្តោតទៅលើតែផលិតផលចិននោះទេ ប៉ុន្តែក្រសួងពាណិជ្ជកម្មចិន បានបង្ហាញការមិនពេញចិត្តយ៉ាងខ្លាំងចំពោះទង្វើបែបនេះ។ ក្រោយមក លោក ត្រាំ បានបញ្ជាឱ្យតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក (USTR) ដាក់ពន្ធលើទំនិញនាំចូលពីប្រទេសចិនដែលមានតម្លៃប្រហែល ៥០ ពាន់លានដុល្លារអាមេរិក បន្ទាប់ពីតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក បានបញ្ចប់ការស៊ើបអង្កេតទៅលើចោរកម្មកម្មសិទ្ធិបញ្ញា។

**ការដាក់ពន្ធទៅវិញទៅមក៖** នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ចិនមិនអាចទ្រាំទ្រនឹងការវាយប្រហាររបស់អាមេរិកបន្តទៀត ហើយក៏បានសម្រេចចិត្តធ្វើការតបតនឹងសហរដ្ឋអាមេរិកវិញដោយពេញទំហឹង។ ចិនបានប្រកាសពីការតម្លើងពន្ធទៅដល់ ២៥ភាគរយ លើផលិតផលរបស់សហរដ្ឋអាមេរិកចំនួន ១២៨មុខ ដោយមានរាប់បញ្ចូលទាំងសាច់ជ្រូកកក ស្រា ផ្លែឈើ និងគ្រាប់ធញ្ញជាតិ។ ចាប់ពីពេលនោះមក ស្ថានភាពនៃការដាក់បន្ថែមពន្ធទៅវិញទៅមកចេះតែបន្ត ហើយប្រទេសទាំងពីរបានចាប់ផ្តើមបាញ់មុខព្រួញដាក់គ្នាទៅវិញទៅមក និងពង្រីកបញ្ជីនៃមុខទំនិញដែលត្រូវស្ថិតក្រោមតម្លៃពន្ធខ្ពស់ ដែលស្ទើរតែគ្រប់ទំនិញនាំចូលដោយក្នុងនោះរួមមាន ផលិតផលកសិកម្ម រថយន្ត ផលិតផលពីសមុទ្រ សម្ភារគីមី និងសម្ភារសំណង់ វាយនភណ្ឌ និងផលិតផលប្រើប្រាស់ប្រចាំថ្ងៃជាច្រើនផ្សេងទៀត។ ពេលដែលផលប៉ះពាល់នៃការតម្លើងពន្ធបានលេចចេញឡើងម្តងបន្តិចៗ ទាំងលោក ត្រាំ និងលោក ស៊ី សុទ្ធតែបានយល់ច្បាស់អំពីផលវិបាកដ៏អាក្រក់នេះ ប៉ុន្តែគ្មាននរណាម្នាក់ស្ម័គ្រចិត្តដកថយមួយជំហានឡើយ ស្របពេលការពិភាក្សាពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដែលបានធ្វើឡើងជាច្រើនលើកច្រើនសារ សុទ្ធតែក្លាយជាអសារបង់។

### ❖ ផលប៉ះពាល់នៃសង្គ្រាមពាណិជ្ជកម្មអាមេរិក និងចិនលើពាណិជ្ជកម្មអន្តរជាតិ និងសេដ្ឋកិច្ចពិភពលោក

គិតត្រឹមពេលនេះ ទីក្រុងវ៉ាស៊ីនតោន និងទីក្រុងប៉េកាំងកំពុងគំរាមកំហែងគ្នាទៅវិញទៅមក ជាមួយនឹងទឹកប្រាក់យ៉ាងហោចណាស់ ២៥០ ពាន់លានដុល្លារអាមេរិក ជាតម្លៃនៃការតម្លើងពន្ធបន្ថែម។ តែសង្គ្រាមពាណិជ្ជកម្មរបស់លោក ត្រាំ បានបង្ហាញពីបរាជ័យនៃគោលនយោបាយការពារនិយមរបស់ខ្លួន។ ឱនភាពពាណិជ្ជកម្មរបស់អាមេរិក បានឈានដល់កំណត់ត្រាខ្ពស់បំផុតក្នុងរយៈពេលដប់ឆ្នាំចុងក្រោយ ដែលសរុបជាទឹកប្រាក់ ៨៩១ ពាន់លានដុល្លារអាមេរិក (Tankersley & Swanson, 2019) ដែលជាហេតុធ្វើឱ្យលោក ត្រាំ ស្ថិតក្នុងស្ថានភាពដ៏លំបាកមួយ ដោយសារដែលគាត់ធ្លាប់បានបង្ហោះក្នុងគណនីសង្គមរបស់គាត់ថា "សង្គ្រាមពាណិជ្ជកម្ម គឺជារឿងល្អ និងងាយស្រួលយកឈ្នះ"។ តែអ្វីដែលអាក្រក់ជាងនេះទៅទៀតនោះ គឺសង្គ្រាមពាណិជ្ជកម្ម បានធ្វើឱ្យ

កសិករជនជាតិអាមេរិកទទួលរងគ្រោះខ្លាំងជាងគេ ដោយសារតែការតបតពន្ធពីចិន។ អ្នកខ្លះបានត្រៀមខ្លួនរួចជាស្រេច ក្នុងការឈប់ប្រកបរបរកសិកម្ម ខណៈពេលដែលអ្នកផ្សេងទៀតបានលក់គ្រឿងម៉ាស៊ីនរបស់ពួកគេ និងបានដាក់ជីរបស់ពួកគេសម្រាប់ជួលអស់ទៅហើយ។ ឯចិនវិញក៏មិនខុសគ្នាប៉ុន្មានដែរ។ ទិន្នន័យមួយបានបង្ហាញថា ចិនមានកំណើនសេដ្ឋកិច្ចកម្រិតទាបបំផុតក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ដោយផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ២០១៨ មានការកើនឡើងតែ ៦.៦% ប៉ុណ្ណោះ គឺធ្លាក់ចុះ ០.២% ពីមុនឆ្នាំ ដែលករណីនេះមិនធ្លាប់មានតាំងពីឆ្នាំ១៩៩០ (Harada, 2019)។ ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចនេះ គឺត្រូវបានគេរំពឹងថានឹងបន្តរហូតដល់ឆ្នាំ២០១៩ និង២០២០ ប្រសិនបើសង្គ្រាមពាណិជ្ជកម្មមិនត្រូវបានដោះស្រាយនោះទេ។ ទីផ្សារហ៊ុនដ៏ធំមួយនៅសៀងហៃឈ្មោះ Shanghai Composite ក៏មានការធ្លាក់ចុះផ្នែកប្រតិបត្តិការផងដែរ ហើយទីផ្សារហ៊ុនមួយនេះរឹតតែរងការគំរាមកំហែងបន្ថែមទៀត ក្រោយពេលលោក ត្រាំ បានប្រកាសការតម្លើងពន្ធបន្ថែមលើមុខទំនិញនាំចូលពីចិនដែលមានតម្លៃ ២០០ ពាន់លានដុល្លារអាមេរិក ទៅរហូតដល់ ២៥ ភាគរយ ដែលនេះជាការប្រកាសដែលគេនឹកស្មានមិនដល់ ពីព្រោះថានៅតែបីថ្ងៃទៀតប៉ុណ្ណោះ ពួកគេនឹងត្រូវចូលតុចរចាសារជាថ្មី។ ពេលនេះតម្លៃពន្ធថ្មីកំពុងតែត្រូវបានអនុម័តហើយ។ ដោយមិនចាំយូរ ចិនក៏បានឆ្លើយតបនឹងការតម្លើងពន្ធរបស់អាមេរិក ដោយការតម្លើងពន្ធដូចគ្នាដោយបង្កើនពន្ធដល់ ២៥% ទៅលើទំនិញអាមេរិកដែលមានតម្លៃ ៦០ ពាន់លានដុល្លារអាមេរិក ហើយនឹងមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ តទៅ។ វាបានសបញ្ជាក់ពីបរាជ័យថ្មីមួយទៀត នៃការចរចាពាណិជ្ជកម្មរបស់ប្រទេសទាំងពីរ។ ផលប៉ះពាល់នៃសង្គ្រាមពាណិជ្ជកម្មនេះ ក៏មានវិសាលភាពធំធេងចំពោះសេដ្ឋកិច្ចពិភពលោក និងបរិយាកាសពាណិជ្ជកម្មអន្តរជាតិផងដែរ ដោយសារតែប្រទេសនានា ដែលស្ថិតនៅក្រោមការដាក់ពន្ធរបស់អាមេរិក ក៏បានឆ្លើយតបនឹងការដាក់ពន្ធនេះក្នុងទម្រង់ស្រដៀងគ្នា ជាហេតុបង្កើតឱ្យមានការរាំងស្ទះលើបរិយាកាសពាណិជ្ជកម្ម ដែលពីមុនធ្លាប់តែបើកទូលាយ និងសេរី។ ដោយសារបរិយាកាសពាណិជ្ជកម្មអន្តរជាតិប្រែជាល្អក់កករ សេដ្ឋកិច្ចសកលត្រូវបានរាយការណ៍ថាមានការធ្លាក់ចុះ ដោយក្នុងឆ្នាំ២០១៨ ពិភពលោកមានកំណើនសេដ្ឋកិច្ចតែ៤%ប៉ុណ្ណោះ បើប្រៀបទៅនឹងឆ្នាំ២០១៧ ដែលមានកំណើន៥% (Wallace, 2019)។ ដូចគ្នានេះដែរ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក៏បានកាត់បន្ថយការព្យាករណ៍ កំណើនសេដ្ឋកិច្ចពិភពលោកសម្រាប់ឆ្នាំ២០១៩ មកនៅត្រឹមតែ៣.៥% ដែលការព្យាករណ៍ដំបូងគឺ ៣.៧% ខណៈពេលដែលភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ចពិភពលោកទាំងពីរ នៅតែបន្តកើនឡើង។ លើសពីនេះទៀត លោក Roberto Azevedo ប្រធានអង្គការពាណិជ្ជកម្មពិភពលោក (WTO) បានចាត់ទុកសង្គ្រាមពាណិជ្ជកម្មនេះថា ជាវិបត្តិដ៏អាក្រក់បំផុតសម្រាប់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី ចាប់តាំងពីកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធ និងពាណិជ្ជកម្មនៅឆ្នាំ១៩៤៧ ដោយសារ "គោលការណ៍គ្រឹះមួយចំនួនរបស់អង្គការពាណិជ្ជកម្មពិភពលោក គោលការណ៍នៃកិច្ចសហប្រតិបត្តិការ និងគោលការណ៍នៃការមិនរើសអើង កំពុងរងការប្រឈម និងត្រូវចោទជាបញ្ហា" (Gallas, 2018)។ សង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន មិនត្រឹមតែបង្កជាបញ្ហាក្នុងវិស័យពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប៉ះពាល់ដល់វិស័យឧស្សាហកម្មផ្សេងទៀតផងដែរ។ វាបានបណ្តាលឱ្យមានការជួលរលំទីផ្សារភាគហ៊ុនផ្នែកបច្ចេកវិទ្យា ដោយក្នុងនោះ ក្រុមហ៊ុន Facebook, Amazon, Apple, Netflix និងបណ្តាញរបស់ក្រុមហ៊ុន Google ផ្សេងទៀតបានបាត់បង់តម្លៃជាទឹកប្រាក់ដល់ទៅ ៨០០ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨ (Cowles, 2018)។ ស្ថិតិថ្មីបំផុតបានបង្ហាញថាទីផ្សារភាគហ៊ុននៅតំបន់អាស៊ី ក្នុងនោះមានទីផ្សារភាគហ៊ុនចិនដីគោក ហុងកុង ជប៉ុន កូរ៉េខាងត្បូង និងអូស្ត្រាលីបានធ្លាក់ចុះយ៉ាងខ្លាំង បន្ទាប់ពីចិនបានឆ្លើយតបទៅនឹងការតម្លើងពន្ធរបស់អាមេរិកក្នុងរយៈពេលថ្មីៗនេះ (Huang, 2019)។

ផ្ទុយពីអ្វីដែលលោក ត្រាំ បានលើកឡើងដំបូងទាក់ទងនឹងសង្គ្រាមពាណិជ្ជកម្ម អ្វីដែលជាការពិតនោះគឺ គ្មាននរណាម្នាក់អាចយកឈ្នះក្នុងសង្គ្រាមសេដ្ឋកិច្ចមួយនេះឡើយ ភាគីទាំងអស់សុទ្ធតែរងការខូចខាត មិនថាអាមេរិក ឬចិនខ្លួនឯងផ្ទាល់ ឬអ្នកដែលនៅក្រៅជម្លោះឡើយ។




*Source: Peterson Institute for International Economics, BBC Research*[2]

## ឯកសារយោង


Amadeo, K. (2019). Trade wars and their effect on the Economy and You. *The Balance.* Retrieved from: https://www.thebalance.com/trade-wars-definition-how-it-affects-you-4159973.

Associated Press. (January 21, 2019). IMF cuts forecast for global economic growth in 2019 amid trade tensions. *South China Morning Post.* Retrieved from: https://www.scmp.com/business/article/2183063/imf-cuts-forecast-global-economic-growth-2019-amid-trade-tensions.

Cowles, C. (November 25, 2018). The Week in Business: Stock Market Falters, and the U.S.-China Trade War Brings Drama to the G-20. *The New York Times.* Retrieved from: https://www.nytimes.com/2018/11/25/business/the-week-in-business-stock-market-falters-and-the-us-china-trade-war-brings-drama-to-the-g-20.html.

Gallas, D. (November 30, 2018). WTO chief warns of worst crisis in global trade since 1947. *BBC.* Retrieved from: https://www.bbc.com/news/business-46395379.

Harada, I. (January 21, 2019). China's GDP growth slows to 28-year low in 2018. *Nikkei Asian Review.* Retrieved from: https://asia.nikkei.com/Economy/China-s-GDP-growth-slows-to-28-year-low-in-2018.

Huang, E. (May 13, 2019). Asia stocks decline as US-China trade war heats up. *CNBC.* Retrieved from: https://www.cnbc.com/2019/05/14/asia-markets-us-china-trade-war-currencies-in-focus.html.

McBride, J. & Chatzky, A. (March 08, 2019). The U.S. Trade Deficit: How Much Does It Matter? *Council on Foreign Relations.* Retrieved from: https://www.cfr.org/backgrounder/us-trade-deficit-how-much-does-it-matter.


[2] See more at BBC. (May 14, 2019). *China hits back in trade war with US.* Retrieved from: https://www.bbc.com/news/business-48253002

Tankersley, J. & Swanson, A. (March 06, 2019). In Blow to Trump, America's Trade Deficit in Goods Hits Record $891 Billion. *The New York Times.* Retrieved from: https://www.nytimes.com/2019/03/06/us/politics/us-trade-deficit.html.

Wallace, C. (March 20, 2019). US-China Trade War Hurting The Global Economy. *Forbes.* Retrieved from: https://www.forbes.com/sites/charleswallace1/2019/03/20/us-china-trade-war-hurting-the-global-economy/#5fa6a0457569.

Wiseman, P. (February 06, 2018). Economy: U.S. trade gap hits $566 billion in 2017, highest since 2008.*USA Today*. Retrieved from: https://www.usatoday.com/story/money/economy/2018/02/06/economy-u-s-trade-gap-hits-566-billion-2017-highest-since-2008/310369002/.

Wong, D. & Koty, A. C. (August 31, 2018). The US-China Trade War: Timeline. *China Briefing.* Retrieved from: https://www.china-briefing.com/news/the-us-china-trade-war-a-timeline/.

Cambodia Development Center

Cambodia Development Center (@cdcenter_kh)

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Cambodia Development Center

Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 16 616 951

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center